# ជំនួយស្មារតី

## ស្តីពីសមិទ្ធផលសំខាន់ៗ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តស្ទឹងត្រែង ក្នុងកម្មវិធីសន្និសីទសារព័ត៌មាន ប្រព្រឹត្តទៅនៅទីស្តីការគណៈរដ្ឋមន្ត្រី

## ថ្ងៃចន្ទ ៥កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

## រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣

ជាបឋម ក្នុងនាមថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តស្ទឹងត្រែង សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានដឹកនាំរៀបចំ និងផ្តល់ឱកាសឱ្យគណៈប្រតិភូយើងខ្ញុំបានចូលរួមធ្វើសន្និសីទសារព័ត៌មាន ស្តីពីសមិទ្ធផលដែលខេត្តសម្រេចបាន និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តស្ទឹងត្រែង ដ៏មានអត្ថន័យនាពេលនេះ។

ក្នុងនាមថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ យុវជន សិស្សនិស្សិត និងប្រជាពលរដ្ឋគ្រប់ជនជាតិក្នុងខេត្តស្ទឹងត្រែង ខ្ញុំសូមគោរពដឹងគុណនិងសូមអរគុណយ៉ាងជ្រាលជ្រៅ និងធំធេងបំផុតនូវសន្តិភាព អរគុណនយោបាយឈ្នះ ឈ្នះ ដឹងគុណស្ថាបនិកមគ្គុទ្ទេសក៍ឯក និងប្រតិបត្តិករនយោបាយឈ្នះ ឈ្នះ ដែលបាននាំមកនូវសន្តិភាពពេញលេញ និងមានការអភិវឌ្ឍរីកចម្រើនដូចថ្ងៃនេះ ក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ជាកិច្ចបន្តទៅនេះ ខ្ញុំសូមការអនុញ្ញាតដើម្បីគោរពជម្រាបជូនអំពីស្ថានភាពទូទៅ សមិទ្ធផលសម្រេចបាន និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តស្ទឹងត្រែង ដែលមានដូចតទៅ៖

### I. ស្ថានភាពទូទៅ

ខេត្តស្ទឹងត្រែង ជាខេត្តមួយស្ថិតនៅភាគឦសាននៃប្រទេស មានចម្ងាយ ៤៥៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងជើងជាប់ខេត្តចាំប៉ាសាក់ និងខេត្តអត្តពឺនៃប្រទេសឡាវ ខាងកើតជាប់ខេត្តរតនគិរី ខាងត្បូងជាប់ខេត្តក្រចេះនិងខេត្តមណ្ឌលគិរី ខាងលិចជាប់នឹងខេត្តព្រះវិហារ និងខេត្តកំពង់ធំ។ ខេត្តមានផ្ទៃដី ១២.០១៦គីឡូម៉ែត្រការេ ចែកជា ៦ក្រុង ស្រុក ៣៤ ឃុំ សង្កាត់ ១៣៧ភូមិ មានស្រុក ០២ ជាប់ព្រំដែនឡាវ គឺស្រុកសៀមប៉ាង និងស្រុកបុរីអូរស្វាយសែនជ័យ បច្ចុប្បន្នខេត្តមានប្រជាជន ១៧១.២០៧នាក់ ស្មើនឹង ៤០.៨៨២គ្រួសារ ក្នុងនោះប្រជាពលរដ្ឋមានអាយុ ១៨ឆ្នាំឡើង ៩៨.៥៣៨នាក់ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ ៤% មានដង់ស៊ីតេប្រជាជន ១៤នាក់ ក្នុង១គីឡូម៉ែត្រការេ។

ប្រជាពលរដ្ឋភាគច្រើន រស់នៅចិញ្ចឹមជីវភាពដោយពឹងផ្អែកលើវិស័យកសិកម្ម ដែលមាន ស្រែ ចម្ការ ដាំដំណាំកសិឧស្សាហកម្ម ដំណាំរួមផ្សំ និងការនេសាទជាដើម ក្រៅពីវិស័យ កសិកម្ម មានវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម-សិប្បកម្ម សេវាកម្ម បុគ្គលិកនៃគ្រឹះស្ថាន អង្គភាព ផ្នែកឯកជន និងជាមន្ត្រីរាជការសាធារណៈ។

កំណើនផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់ កើនឡើងពី ១.៤២៣ដុល្លារ ក្នុង ឆ្នាំ២០១៨ ដល់ ១.៥៨៥ដុល្លារ ក្នុងឆ្នាំ២០២៣ និងអត្រាភាពក្រីក្រថយចុះពី ២៣% ក្នុងឆ្នាំ ២០១៨ មកត្រឹម ២១% ក្នុងឆ្នាំ២០២៣។

ខេត្តមានផ្ទៃដីធំទូលាយ ដីមានជីជាតិអំណោយផលដល់ការវិនិយោគលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍។ មានទន្លេ ៤ហូកាត់ ដែលជាប្រភពធនធានធម្មជាតិសំបូរ បែប ប្រភពទឹកប្រើប្រាស់ និងធ្វើកសិកម្ម ជាមូលដ្ឋានតំបន់អេកូទេសចរណ៍ ទីជម្រកសម្រាប់ ការពងកូនរបស់ពពួកត្រីមេពូជ ជាតំបន់ផ្តល់ជីវិតនៃប្រព័ន្ធជីវៈចម្រុះ និងជាអាងស្តុកនៅ ធនធានមច្ឆាជាតិដ៏សំខាន់។ សណ្ឋានដីខេត្តជាតំបន់ខ្ពង់រាប មានព្រៃភ្នំ ទន្លេ ស្ទឹង បឹងបួ អូរនិង ដីកោះច្រើនកន្លែង ដោយបានកំណត់ជាបណ្តុំនៃប្រព័ន្ធអេកូឡូហ្ស៊ី ជីវៈចម្រុះ និងមានតំបន់ ការពារធម្មជាតិច្រើនកន្លែង។

មានទំនប់វារីអគ្គិសនី ១កន្លែង មានអានុភាព ៤០០មេហ្គាវ៉ាត់ ស្ពានឆ្លងកាត់ទន្លេធំៗ ៤ កន្លែង មានស្ពានឆ្លងទន្លេសេកុង ប្រវែង ១.០៥៧ម៉ែត្រ ស្ពានឆ្លងទន្លេមេគង្គ ប្រវែង ១.៧៣១ ម៉ែត្រ ស្ពានទន្លេកុងសែនជ័យ ប្រវែង ២៦០ម៉ែត្រ និងស្ពានកោះទន្សាយសែនជ័យឆ្លងកាត់ទន្លេ កុងផ្នែកខាងលើ ប្រវែង ២៤០ម៉ែត្រ។ ផ្លូវជាតិឆ្លងកាត់ខេត្ត មាន ៣ខ្សែ គឺផ្លូវជាតិលេខ៧ ពីព្រំ ប្រទល់ខេត្តក្រចេះដល់ច្រកទ្វារអន្តរជាតិត្រពាំងក្រៀល ៨៦,៦គីឡូម៉ែត្រ ផ្លូវជាតិលេខ៩ ពីព្រំ ប្រទល់ខេត្តព្រះវិហារ ដល់ក្រុងស្ទឹងត្រែង ៧២,៩គីឡូម៉ែត្រ ផ្លូវជាតិលេខ៧៨ ចាប់ពីអូរពង់មាន់ ក្រុងស្ទឹងត្រែង ដល់ស្ពានស្រែពក ខេត្តរតនគិរី ៦៥គីឡូម៉ែត្រ។

## II. សមិទ្ធផលសំខាន់ៗ

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងការចង្អុលបង្ហាញតម្រង់ទិសដឹកនាំ របស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងការរួមចំណែក អនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា រដ្ឋបាលខេត្តស្ទឹងត្រែង បានខិតខំយកចិត្តទុកដាក់អនុវត្តផែនការ អភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលតាមបណ្តាឆ្នាំនីមួយៗ ដាក់ចេញ នូវផែនការយុទ្ធសាស្ត្រ និងពិសេសចក្ខុវិស័យនានាថែមទៀតដើម្បីថែរក្សាការពារជានាឱ្យបាន នូវសន្តិភាព ស្ថិរភាពសង្គម និងសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ អធិបតេយ្យភាព

បូរណភាពទឹកដី។ លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមលើគ្រប់វិស័យ គោរពច្បាប់និងនីតិរដ្ឋ ធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ ពង្រឹងការផ្តល់សេវាសាធារណៈប្រកបដោយតម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន មានការគ្រប់គ្រង និងអភិរក្សបាននូវធនធានធម្មជាតិបរិស្ថាន វប្បធម៌ប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់ មានការវិវត្តន៍រីកចម្រើនផ្នែកនគរូបនីយកម្ម និងប្រជាជន ជំរុញការកាត់បន្ថយបាននូវអត្រាភាពក្រីក្រ ដើម្បីសុខុមាលភាព វិបុលភាព សុខដុមរមនា និងសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋក្នុងសង្គម។

ក្នុងស្ថានភាពបញ្ហាប្រឈមនៃការរីករាលដាលជំងឺកូវីដ-១៩ ជាសកលនាពេលកន្លងមក ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងសុខាភិបាល រដ្ឋបាលខេត្ត បានបង្កើតយន្តការគ្រប់គ្រង និងអនុវត្តយុទ្ធនាការអប់រំផ្សព្វផ្សាយ ចលនាប្រជាជនចូលរួមក្នុងការលើកកម្ពស់ការថែទាំសុខភាព និងចូលរួមបង្ការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ក្នុងមូលដ្ឋាន និងអនុវត្តវិធានរដ្ឋបាល វិធានការសុខាភិបាល ព្រមទាំងយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋតាមផែនការបានដាក់ចេញ។

សមិទ្ធផលសំខាន់ៗដែលខេត្តសម្រេចបាន ក្នុងការបម្រើផលប្រយោជន៍ជាតិ មាតុភូមិ និងប្រជាជនក្នុងខេត្ត នារយៈពេល ៥ឆ្នាំកន្លងមកនេះ រួមមាន៖

**១-ការដោះស្រាយ អន្តរាគមន៍ និងគ្រប់គ្រងសភាពការណ៍ដើម្បីប្រជាជនក្នុងខេត្ត**

-ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋបាលខេត្តស្ទឹងត្រែង បានយកចិត្តទុកដាក់ខ្ពស់ អន្តរាគមន៍ ដោះស្រាយ ឆ្លើយតប នូវបញ្ហាគ្រោះមហន្តរាយធម្មជាតិជាបន្តបន្ទាប់ ដែលក្នុងមួយឆ្នាំៗមានផលប៉ះពាល់ក្នុងរង្វង់ពី **១ពាន់គ្រួសារ ទៅ៩ពាន់គ្រួសារ** តាមស្ថានភាពនៃទំហំប៉ះពាល់ក្នុងឆ្នាំ។ ដោយបានការឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នថ្នាក់ជាតិ ពិសេសគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ កាកបាទក្រហមកម្ពុជា គណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្នុងខេត្ត ក្រៅខេត្ត ព្រមទាំងសប្បុរសជននានា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត បានអនុវត្តផែនការអន្តរាគមន៍ឆ្លើយតប និងសង្គ្រោះប្រជាពលរដ្ឋក្នុងតំបន់រងផលប៉ះពាល់ បានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

-ក្នុងដំណាក់កាលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ មានប្រជាពលរដ្ឋនៅទូទាំងខេត្តបានឆ្លងជំងឺដ៏កាចសហាវនេះចំនួន **២.១៩២នាក់** ក្នុងនោះបានមរណភាព **៣៣នាក់** ទន្ទឹមនោះ ដោយមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធមានសមត្ថកិច្ច និងក្រុមយុវជនក្នុងខេត្ត ពិសេសក្រុមគ្រូពេទ្យ បានរួបរួមជាកម្លាំងស្នូល អនុវត្តវិធានការរដ្ឋបាល និងវិធានការសុខាភិបាលព្រមៗគ្នា នៅគ្រប់ទីកន្លែង ក្នុងកិច្ចការពារអាយុជីវិតប្រជាជន និងសុខភាពសាធារណៈប្រកបដោយប្រសិទ្ធភាព សាមគ្គីភាព ឯកភាពរឹងមាំ និងបានជំរុញការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រេចបានសម្រាប់ដូសមូលដ្ឋានជាង ១០ម៉ឺននាក់ និងដូសជំរុញប្រមាណ ១០ម៉ឺននាក់។

-គិតត្រឹមថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-១៩ សម្រេចបាន ១០.១៧០គ្រួសារ មានទឹកប្រាក់ស្មើនឹង ៥៨.៣៩៤.៦៤៦.០០០រៀល (ហាសិបប្រាំបីប៊ីលាន បីរយកៅសិបបួនលាន ប្រាំមួយរយសែសិបប្រាំមួយពាន់រៀល) និងស្ត្រីមានផ្ទៃនិងកុមារក្រោមអាយុ២ឆ្នាំ ចំនួន ៣.៥៦២នាក់ មានទឹកប្រាក់ ១.៤០៥.៩២០.០០០រៀល (មួយប៊ីលាន បួនរយប្រាំលាន ប្រាំបួនរយម្ភៃពាន់រៀល)។

-ការគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាព ព្រមទាំងផ្តល់ប័ណ្ណគ្រួសារប្រជាពលរដ្ឋក្រីក្រក្នុងខេត្ត សម្រាប់កម្រិត១ ចំនួន ៣.៧៣៩គ្រួសារ និងកម្រិត២ ចំនួន ៦.១៨៤គ្រួសារ។

-ជំរុញការផ្តល់ប័ណ្ណសមាជិក ប.ស.ស ជូនមន្ត្រីរាជការ អតីតមន្ត្រីរាជការ អតីតយុទ្ធជន និងមន្ត្រីកិច្ចសន្យា ដោយមិនគិតថ្លៃ លើផ្នែកហានិភ័យការងារ ៣.២៤០នាក់ ផ្នែកថែទាំសុខភាព ៤.៩៥២នាក់ និងកម្មករនិយោជិត ៤.០៤៣នាក់។ សម្រាប់រយៈពេល ៥ឆ្នាំកន្លងមកនេះ បានអន្តរាគមន៍ដល់អ្នកប្រើប្រាស់សេវាថែទាំសុខភាពដោយឥតគិតថ្លៃ ក្នុងនោះវិស័យឯកជន ១.០៨៤ករណី ស្មើនឹង ១.០៣៨នាក់ វិស័យសាធារណៈ ៣.០២៧ករណី មាន ២.៧៥៩នាក់ និងអ្នកប្រើប្រាស់សេវាផ្នែកហានិភ័យការងារវិស័យឯកជន ៣៤ករណី មាន ៣៤នាក់។ ការផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលជូនដល់ស្ត្រីសម្រាលកូនសរុប **៤១០នាក់** ស្មើនឹងទឹកប្រាក់សរុបចំនួន ១៦៦លានរៀល។

**២-សមិទ្ធផលសំខាន់នៃវិស័យសាធារណៈក្នុងការលើកកម្ពស់សេដ្ឋកិច្ចសង្គមក្នុងខេត្ត**

-ជានាពង្រឹងការគ្រប់គ្រងជាប់ជាប្រចាំសន្តិសុខ សណ្តាប់សាធារណៈ សុវត្ថិភាពសង្គមក្នុងខេត្ត និងនៅតាមតំបន់ព្រំដែន។ ជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពនៅថ្នាក់ឃុំ សង្កាត់ និងនៅតាមបណ្តាភូមិ ព្រមទាំងសហគមន៍។ អនុវត្តវិធានការបង្ក្រាបបទល្មើស ការប្រយុទ្ធប្រឆាំងនឹងបទល្មើសគ្រឿងញៀន ការប្រយុទ្ធប្រឆាំងនឹងបទល្មើសជួញដូរមនុស្ស និងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ព្រមទាំងពង្រឹងការគ្រប់គ្រងសភាពការណ៍សន្តិសុខ សុវត្ថិភាពក្នុងដំណាក់កាលនៃការបោះឆ្នោតនីមួយៗ។ ជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ និងការគ្រប់គ្រងជនអន្តោប្រវេសន្តតាមគោលការណ៍។

-ការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយខេត្តជាប់ព្រំដែន ដែលមានខេត្តចម្ប៉ាសាក់ និងខេត្តអត្តពឺប្រទេសឡាវ និងខេត្តសម្ព័ន្ធភាពមានកិច្ចសហប្រតិបត្តិការដែលមានខេត្តកន្ទូម ខេត្តយ៉ាឡាយ ខេត្តខាញ់ហ័រ និងខេត្តប៊ិញហ្សឿក នៃប្រទេសវៀតណាម។

-ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ការអនុវត្តផែនការសកម្មភាពការងារក្នុងក្របខ័ណ្ឌ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងការផ្តល់សេវាសាធារណៈគ្រប់វិស័យ ព្រមទាំងសេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ជាមធ្យមជាង **៥ពាន់សេវារដ្ឋបាល**ក្នុង១ឆ្នាំៗ។

-ការគ្រប់គ្រង និងរៀបចំរដ្ឋបាលដែនដីនៅមូលដ្ឋាន ក្នុងនោះបានស្នើសុំរៀបចំបង្កើតនូវស្រុកថ្មីចំនួនមួយ នៅជាប់ព្រំដែនកម្ពុជា-ឡាវ និងការបង្កើតភូមិថ្មីចំនួន ៩ភូមិ ក្នុងឃុំ សង្កាត់មួយចំនួន៤។

-ហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍សម្រេចបានក្នុងរយៈពេល៥ឆ្នាំកន្លងមក ក្នុងនោះមានគម្រោងថវិកាខេត្ត មូលនិធិក្រុង ស្រុកទាំង៦ និងឃុំ សង្កាត់ទាំង៣៤ រួមមាន ផ្លូវកៅស៊ូ ៣១គីឡូម៉ែត្រ ផ្លូវបេតុង ៦គីឡូម៉ែត្រ ផ្លូវក្រួសក្រហម ១១៩គីឡូម៉ែត្រ ស្ពានធំៗ ៨កន្លែង លូប្រអប់ ៤២កន្លែង និងលូកាត់ផ្លូវ ៧៦៥កន្លែង។ គម្រោងមន្ទីរជំនាញសរុបមាន ផ្លូវកៅស៊ូ ០២ខ្សែ ប្រវែង ២៣,១២គីឡូម៉ែត្រ ផ្លូវបេតុង ០២ខ្សែ ប្រវែង ២២គីឡូម៉ែត្រ ស្ពានបេតុង ១៧កន្លែង ប្រវែង ៦៥៦ម៉ែត្រ ជាឡូ-លូប្រអប់ ១១កន្លែង ជួសជុលកែលម្អស្តារឡើងវិញផ្លូវក្រួសក្រហម ក្នុងមូលដ្ឋាន ២៧ខ្សែ ប្រវែង ២៧៥គីឡូម៉ែត្រ។

-ក្នុងមួយឆ្នាំៗមានផ្ទៃដីបង្កបង្កើនផលស្រូវ ២៧.៨០០ហិកតា មានបរិមាណផលស្រូវប្រមាណ ៧៣.០០០តោន។ ដំណាំសាកវប្បកម្មមានជាង ៤.០០០ហិកតា ទទួលបានផលក្នុងរង្វង់ ៤៥.០០០តោន។ ដំណាំឧស្សាហកម្មជាដំឡូងមី សណ្តែកដី សណ្តែកសៀង អំពៅ ល្ង ជាដើមមាន ២៦.០០០ហិកតា ទទួលផល ៥.០០០តោន។ ការប្រមូលផល-លក់ចេញគ្រាប់ស្វាយចន្ទីប្រមាណ ២៥.០០០តោន និងស្វាយកែវរមៀតជាង ១.៥០០ពាន់តោន។ ផលិតកម្មដំណាំកៅស៊ូលើផ្ទៃដី ៧១.០៩៥ពាន់ហិកតា ផ្ទៃដីចៀរជ័រ ២១.៩៥៣ហិកតា ទទួលបាលផលិតផលជ័រកៅស៊ូជាង ២៣.៧១៦តោន។ ផលិតកម្មសត្វជាលក្ខណៈគ្រួសារ និងអាជីវកម្មបានកើនឡើងដល់ជាង ៩០០.០០០ក្បាល ដើម្បីផ្គត់ផ្គង់តម្រូវការដែលកើនឡើងដល់ជិត ៣.០០០តោន។ ផលនេសាទទឹកសាប និងវារីវប្បកម្មសម្រេចបាន ៤.០០០តោន ក្នុងមួយឆ្នាំ។

-តភ្ជាប់ និងពង្រីកខ្សែបណ្តាញអគ្គិសនីទៅដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ក្នុងខេត្តសម្រាប់តង់ស្យុងមធ្យមសម្រេចបាន ៩១៥គីឡូម៉ែត្រ និងតង់ស្យុងទាបសម្រេចបាន ៥៤២គីឡូម៉ែត្រ សរុបអ្នកបានទទួលសេវាប្រើប្រាស់អគ្គិសនីចំនួន ១៥.៤៣៦អ្នកប្រើប្រាស់។

-រៀបចំឡើងវិញនូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតថ្មីតាមបទដ្ឋានថ្មីក្នុងក្រុងស្ទឹងត្រែង និងពង្រីកទៅទីប្រជុំជននៃស្រុកមួយចំនួននៅជិតក្រុងស្ទឹងត្រែង ដែលមានសមត្ថភាពធ្វើការផ្គត់ផ្គង់បាន **ពី១២.០០០ ទៅ ១៥.០០០ម៉ែត្រគូប**ក្នុងមួយថ្ងៃ។

-ពង្រឹងពង្រីកការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្រ្ត ក្នុងមូលដ្ឋានកើនឡើងដល់ចំនួន ១២កន្លែង សម្រាប់ការជួយសម្រួលផ្តល់ទឹកស្រោចស្រពផ្ទៃដីបង្កបង្កើនផលដំណាំរបស់ប្រជាជនក្នុងមូលដ្ឋានភូមិ ឃុំ សង្កាត់។

-ក្នុងភូមិសាស្រ្តខេត្តមានមូលដ្ឋាន និងសហគមន៍អេកូទេសចរណ៍ធម្មជាតិ ប្រវត្តិសាស្រ្ត និងវប្បធម៌សំខាន់ៗចំនួន ១២កន្លែង ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិក្នុងមួយឆ្នាំៗប្រមាណពី ១២០.០០០នាក់ ទៅ ១៦០.០០០នាក់។

-បានពង្រីកវិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធអប់រំដល់គ្រប់មូលដ្ឋាន រួមមានអគារសិក្សាបានកើនឡើងដល់ចំនួន ៤១៦ខ្នង ស្មើនឹង ១.៧០៦បន្ទប់ក្នុងទូទាំងខេត្ត រួមមានអគារមត្តេយ្យសិក្សា ៣ខ្នង មាន១៤បន្ទប់ បឋមសិក្សា ២៩២ខ្នង មាន១.១៥៤បន្ទប់ អនុវិទ្យាល័យ ៤៣ខ្នង មាន ២០១បន្ទប់ វិទ្យាល័យ ៧៨ខ្នង មាន ៣៣៤បន្ទប់ និងមានរោងជោលចំនួន ១៤ខ្នង។ ក្នុងនោះអគារសិក្សាជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រានី ហ៊ុន សែន** មាន **៦០ខ្នង ស្មើនឹង ៣៦៧បន្ទប់**។ បុគ្គលិកសិក្សាអប់រំ គ្រូបង្រៀនគ្រប់កម្រិត មានចំនួន ១.៦៨១នាក់ ស្រី ៨៤៤នាក់ គ្រូបង្រៀនថ្នាក់ពហុភាសា ៣២នាក់ ស្រី ០៨នាក់ និងគ្រូជាប់កិច្ចសន្យា ៤៥២នាក់។ សិស្សក្នុងឆ្នាំសិក្សាកន្លងមកនៅគ្រប់កម្រិតសរុប ៤០.២២១នាក់ ស្រី ២០.២៨៥នាក់ និងសម្រាប់សិស្សថ្នាក់ពហុភាសាមានចំនួន ៦១២នាក់ ស្រី ៣០៤នាក់។ ខេត្តមានមជ្ឈមណ្ឌលគរុកោសល្យភូមិ ១កន្លែងបណ្តុះបណ្តាលគរុសិស្សបឋមសិក្សា សម្រាប់ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី សកលវិទ្យាល័យឯកជន ១កន្លែង និងសាលារៀនឯកជន ០៤កន្លែង។

-ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ខេត្តបានខិតខំប្រឹងប្រែងជំរុញការអភិវឌ្ឍ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសុខាភិបាលជាបន្តបន្ទាប់នៅមន្ទីរពេទ្យ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព ទាំងក្នុងដំណាក់កាលឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងស្ថានភាពគ្រោះអាសន្នកើតមានឡើង។ ក្នុងខេត្តមានមន្ទីរពេទ្យបង្អែកខេត្ត ១កន្លែង មណ្ឌលសុខភាព ១៩កន្លែង ប៉ុស្តិ៍សុខភាព ៤កន្លែង ដែលអាចផ្តល់សេវាសុខាភិបាលនិងការងារសុខភាពសាធារណៈជូនប្រជាពលរដ្ឋ ប្រមាណ ៧.៥០០នាក់ ទៅ ៩.០០០នាក់ ក្នុង១ឆ្នាំៗ។ ខេត្តមានសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ១កន្លែង ដែលបានជួយបណ្តុះបណ្តាលសិស្សនិស្សិតផ្នែកជំនាញវិជ្ជាជីវៈសុខាភិបាលកម្រិតបឋម និងមធ្យម សម្រាប់ខេត្តស្ទឹងត្រែង ក្រចេះ ព្រះវិហារ រតនគិរី និងមណ្ឌលគិរី។

-លើកកម្ពស់ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតឱកាសការងារ តាមរយៈការអនុវត្តកម្មវិធីបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្ត និងការផ្សព្វផ្សាយ ស្វែងរកងារធ្វើនៅមជ្ឈមណ្ឌលការងារនិងមុខរបរ។

-បង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីដីធ្លីសម្រាប់ការគ្រប់គ្រង ប្រើប្រាស់ និងអាស្រ័យផលលើដីកម្មសិទ្ធិស្របច្បាប់ ក្នុងនោះមាន ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានសម្រេចបាន ៣៥ភូមិ ដោយបានផ្តល់ប័ណ្ណកម្មសិទ្ធិរួចរាល់ ៣៤.១២៥ប័ណ្ណ។ ចុះបញ្ជីក្បាលដីគម្រោងសម្បទានដីសេដ្ឋកិច្ច ដោយបានចេញប័ណ្ណលើក្បាលដីចំនួន ១១ទីតាំង ស្មើនឹង ១៥១ប័ណ្ណ មានទំហំសរុប ១១៦.៣៦៨ហិកតា និងបន្តវាស់វែង ២ទីតាំង មានទំហំដីសរុប ៩៤.០០០ហិកតា។ ពង្រឹងការគ្រប់គ្រងទីតាំងដីសម្បទានសង្គមកិច្ចចំនួន ៧ទីតាំង ស្មើនឹងទំហំសរុបជាង ១ម៉ឺន៤ពាន់ហិកតា។ ចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិចចំនួន

៤សហគមន៍ បានចេញប័ណ្ណដីជាសមូហភាព ២សហគមន៍ និងត្រៀមចេញជូន ២សហគមន៍ទៀតក្នុងពេលខាងមុខនេះ។

-ពង្រឹងការគ្រប់គ្រងតំបន់ការពារធនធានធម្មជាតិក្នុងភូមិសាស្ត្រខេត្ត ដែលរួមមានតំបន់ឧទ្យានជាតិវីរៈជ័យ ផ្ទៃដីជា ៩៩ពាន់ហិកតា ឧទ្យានជាតិវីរៈសៃ-សៀមប៉ាង ផ្ទៃដីជាង ៤៤ពាន់ហិកតា ដែនជម្រកសត្វព្រៃ-ព្រៃឡង់ ផ្ទៃដីជាង ១២១ពាន់ហិកតា ដែនជម្រកសត្វព្រៃសៀមប៉ាង មានផ្ទៃដីជាង ១៣៣ពាន់ហិកតា និងតំបន់រាមសារ ផ្ទៃដី ១៤.៦០០ហិកតា។ ដោយឡែកតំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គក្នុងខេត្តតាមបណ្តោយទន្លេមេគង្គ ៣៥គីឡូម៉ែត្រ និងមានតំបន់ដែលបានកំណត់ជាកន្លែងអភិរក្ស និងកន្លែងការពារមានទំហំជាក់ស្តែង ផ្អែកទៅតាមចលនានៃការរស់នៅ ការបន្លាស់ទី ការស្វែងរកចំណី និងការបន្តពូជរបស់សត្វផ្សោត។

-ជាមួយគ្នានេះសម្រាប់វិស័យផ្សេងៗទៀតដែលពុំបានបង្ហាញជូនខាងលើនេះ ក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការដឹកនាំ គ្រប់គ្រង និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងខេត្តឱ្យមានការរីកចម្រើនឡើងផងដែរ។

-ខ្ញុំបាទសូមគោរពជម្រាបជូន មេត្តាជ្រាបថា សមិទ្ធផលដែលបានរំលេចជូនខាងលើនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងអភិវឌ្ឍក្រោមស្នាដៃ ដោយគណៈអភិបាលអាណត្តិមុនរួមទាំងសមិទ្ធផលដែលកើតឡើងជាបន្តបន្ទាប់ក្នុងអាណត្តិបច្ចុប្បន្ន ដែលរូបខ្ញុំផ្ទាល់បានគ្រប់គ្រងដឹកនាំអភិវឌ្ឍទើបបានតែរយៈពេល ១ឆ្នាំកន្លះប៉ុណ្ណោះ។

### III. ទិសដៅការងារបន្ត

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ ខេត្តក៏មានផែនការ និងយុទ្ធសាស្ត្រជាច្រើនទៀត ដែលបានដាក់ចេញ និងបន្តអនុវត្តដូចតទៅ៖

១.ក្តាប់ជាប់សភាពការណ៍ទូទៅ និងខិតខំថែរក្សា ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឱ្យបានកាន់តែរឹងមាំ ធានាការពារប្រក្រតីភាពនៃស្ថាប័ន មន្ទីរ អង្គភាពជុំវិញខេត្ត រដ្ឋបាលមូលដ្ឋានក្រុង ស្រុក និងឃុំ សង្កាត់ ជាពិសេសធានាគ្រប់គ្រងថែរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពឱ្យបានរឹងមាំ ទាំងមុនពេល ក្នុងពេល និងក្រោយពេលនៃដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនឹងឈានចូលមកដល់នៅ**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣**ខាងមុខនេះ។

២.បន្តពង្រឹងប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទដែលបង្កអសន្តិសុខដល់សង្គមជាតិ តាមរយៈការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពជាប្រចាំប្រកបដោយភាពម៉ឺងម៉ាត់ ហ្មត់ចត់ រឹងមាំ មុតស្រួច និងមានប្រសិទ្ធភាព។

៣.ជំរុញផែនការលើកកម្ពស់វិស័យកសិកម្ម កសិឧស្សាហកម្ម ទេចរណ៍ និងការបង្កើតមុខរបរដល់កម្លាំងពលកម្មក្នុងមូលដ្ឋាន តាមរយៈការបណ្តុះបណ្តាលជំនាញបច្ចេកទេសមូលដ្ឋាន

ការទំនាក់ទំនងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនដើម្បីកៀរគរការវិនិយោគបង្កើនផលិតផលពាក់កណ្តាលសម្រេច និងផលិតផលសម្រេចនៅក្នុងកម្រិតមួយសម្រាប់ការបង្កើនប្រាក់ចំណូល និងជីវភាពរស់នៅរបស់ប្រជាជន។

៤.បន្តពិនិត្យ និងដោះស្រាយសំណើ សំណូមពរ បញ្ហាប្រឈម និងកង្វល់នានាដែលប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានទៅតាមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ស្ថាប័ន មន្ទីរ អង្គភាព រដ្ឋបាលមូលដ្ឋាន សមស្របតាមច្បាប់ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្ត។

៥.ជំរុញការរួមចំណែកអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា និងការអនុវត្តក្របខ័ណ្ឌគោលនយោបាយរបស់ជាតិ ដែលមានគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ គោលនយោបាយជាតិគាំពារសង្គមឱ្យកាន់តែមានវិសាលភាព និងប្រសិទ្ធភាព។

៦.ពិនិត្យលទ្ធភាព និងសិក្សាអនុវត្តគោលនយោបាយជួយដល់ប្រជាកសិករ ដើម្បីថែរក្សាស្ថិរភាពថ្លៃកសិផល និងការពង្រីកទីផ្សារកសិផល ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មដើម្បីរួមចំណែកដ៏មានអាទិភាពអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ និងគ្រួសារប្រជាពលរដ្ឋ។

៧.ជំរុញសកម្មភាពលើកកម្ពស់ទីក្រុងស្អាត ដោយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការកែលម្អសោភ័ណភាពទីប្រជុំជនក្រុង និងស្រុក ឱ្យបានស្រស់ស្អាត ដែលជាផ្នែកមួយក្នុងការនាំមកនូវផាសុខភាពជូនប្រជាជន និងការទាក់ទាញភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ។

៨.ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាខេត្តនៃប្រទេសស្ថិតក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម (CLV) ឱ្យកាន់តែល្អប្រសើរ និងខិតខំទាញយកការវិនិយោគសាធារណៈ និងវិនិយោគឯកជនតាមរយៈសន្និសីទ កិច្ចប្រជុំ និងការធ្វើទស្សនកិច្ចជាមិត្តភាព។

៩.អនុវត្តរបបប្រជុំប្តូរវេនជាមួយបណ្តាខេត្ត នៃប្រទេសជាប់ព្រំដែនភូមិផងរបងជាមួយ ព្រមទាំងពិនិត្យ និងដាក់ចេញនូវកំណត់ហេតុកិច្ចសហប្រតិបត្តិការ ឈានទៅធ្វើឱ្យមានការកើនឡើងការវិនិយោគអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ធានាការថែរក្សាបាននូវអធិបតេយ្យភាពជាតិ បូរណភាពទឹកដី តុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងខេត្តនឹងខេត្ត។

១០.ពង្រីកវិសាលភាពការអភិវឌ្ឍ និងស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមនៅគ្រប់មូលដ្ឋាន ពង្រឹងការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធានមនុស្សគ្រប់វិស័យ និងឆ្លើយតបតម្រូវការរបស់រដ្ឋបាលមូលដ្ឋាន។

១១.ត្រៀមបង្ការនូវហានិភ័យនានាដែលអាចបង្កឡើង ធ្វើឱ្យប៉ះពាល់ដល់សុខសុវត្ថិភាព និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ពិសេសគ្រោះមហន្តរាយធម្មជាតិ និងបម្រែបម្រួលអាកាសធាតុដើម្បីថែរក្សា និងលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាពលរដ្ឋ។

១២.លើកកម្ពស់ប្រសិទ្ធភាព គុណភាព និងភាពស្អាតស្អំ ដោយអនុវត្តតាមអភិក្រមទាំងប្រាំ គឺឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ ក្នុងការផ្តល់សេវាសាធារណៈដែលជាកាតព្វកិច្ចរបស់រដ្ឋ និងជាសេចក្តីត្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយផ្តោតលើវិស័យអប់រំ សុខាភិបាល ការដោះស្រាយវិវាទដីធ្លី និងសេវាសាធារណៈគ្រប់ប្រភេទរបស់មន្ទីរ អង្គភាពជុំវិញខេត្ត និងរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ តាមរយៈយន្តការច្រកចេញចូលតែមួយ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពថ្លែងអំណរគុណដល់អង្គសន្និសីទទាំងមូល ក៏ដូចជាទូរទស្សនិកជនទាំងអស់ ដែលកំពុងតាមការផ្សាយបន្តផ្ទាល់កម្មវិធីសន្និសីទសារព័ត៌មាន និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** និងជា **ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** ព្រមទាំងសហការី និង**ឯកឧត្តម លោកជំទាវ លោក លោកស្រី**ទាំងអស់ សូមមានសុខភាពល្អបរិបូរណ៍ ជោគជ័យគ្រប់ភារកិច្ច និងសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

***សូមគោរពថ្លែងអំណរគុណ និងអរគុណ!***